**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៥ កយ.សសរ.ប/១៤

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោតលើកទី ១ ជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញប្រកាសលេខ ១០៣ កយ.ប្រក/១៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៤ របស់ក្រសួងយុត្តិធម៌ ស្តីពីបែបបទ និងនីតិវិធីនៃការបោះឆ្នោតលើកទី ១ សម្រាប់ការជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១ ._**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោតលើកទី ១ ជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចខាងក្រោម ៖

| | |
|---|---|
| - ឯកឧត្តម **អង្គ វង្សវឌ្ឍានា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |
| - ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធានប្រចាំការ |
| - ឯកឧត្តម **ជីវ កេង** អនុប្រធានតុលាការកំពូល | អនុប្រធាន |



មហាវិថីសម្តេចសុធារស.ខណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841

- ឯកឧត្តម **សេង ប៊ុនឃាង** អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល អនុប្រធាន
- ឯកឧត្តម **កើត រិទ្ធ** តំណាងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សមាជិក
- ឯកឧត្តម **អ៊ិត រ៉ាឌី** តំណាងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សមាជិក
- ឯកឧត្តម **យូ ប៊ុនឡេង** ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ សមាជិក
- ឯកឧត្តម **អ៊ឹក សាវុធ** អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ សមាជិក
- លោក **អាំង មាលតី** ប្រធានសាលាដំបូងរាជធានីភ្នំពេញ សមាជិក
- ឯកឧត្តម **យ៉េត ចរិយា** ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ សមាជិក
- ឯកឧត្តម **សំ ប្រជាមានិត** អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិក។

**ប្រការ ២ .-**

ត្រូវបានតែងតាំងសមាសភាពលេខាធិការនៃគណៈកម្មការរៀបចំការបោះឆ្នោតលើកទី ១ ជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចខាងក្រោម ៖

- លោក **សំ សុក្រជាតិ** អនុប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច
- លោក **សុង សុខភារម្យ** អនុប្រធាននាយកដ្ឋានជំនួយការកិច្ចការតុលាការ
- លោកស្រី **ថន សុធាវី** អនុប្រធានការិយាល័យទទួលពាក្យបណ្តឹង
- កញ្ញា **គា មុីមុី** លេខាធិការផ្ទាល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- លោក **ឡាយ លាងសេង** មន្ត្រីនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ។

**ប្រការ ៣ .-**

ខុទ្ទកាល័យ អគ្គាធិការដ្ឋានកិច្ចការតុលាការ គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន ចំណុះក្រសួងយុត្តិធម៌ សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍនៈ

**កន្លែងទទួល ៖**

- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ